**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ
# ស្តីពី
# ករណីរោងចក្រ បូអ៊ី ហ្គាម៉ិន ៦.ក

ឆ្នាំពីរពាន់ម្ភៃបី ខែកុម្ភៈ ថ្ងៃទីម្ភៃពីរ វេលាម៉ោង ប្រាំបួន និងដប់នាទីព្រឹកនៅក្នុងបន្ទប់ប្រជុំលេខ១ នៃរោងចក្រ បូអ៊ី ហ្គាម៉ិន ៦.ក បានបើកកិច្ចប្រជុំមួយស្តីពី ព្យួរកិច្ចសន្យាការងារ នៅក្នុងរោងចក្រ បូអ៊ី ហ្គាម៉ិន ៦.ក ដែលមានអាសយដ្ឋានស្ថិតនៅ ភូមិជង្រុក សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ។

**I- សមាសភាពចូលរួមប្រជុំ**

១- នាយកក្រុមហ៊ុន

២- អ្នកបកប្រែភាសាចិន

៣- រដ្ឋបាល

៤- ប្រតិភូបុគ្គលិក

៥- ប្រធានផ្នែក ប្រធានក្រុម

(មានភ្ជាប់ជូននូវបញ្ជីវត្តមាន)

**II- របៀបវារៈ**

ករណីកម្មករ និយោជិត មានកិច្ចប្រជុំពិភាក្សា រវាងនាយក្រុមហ៊ុន និងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារ ដោយមូលហេតុនៅពេលថ្មីៗនេះ ដោយសារតែកង្វះការបញ្ជាទិញ ដែលជាបញ្ហាដ៏ធំមួយធ្វើឲ្យមានបញ្ហាស្ទះលំហូរផលិតកម្មយ៉ាងធ្ងន់ធ្ងរ ។

**III- យន្តការ និងដំណើរការដោះស្រាយ**

ជាកិច្ចចាប់ផ្តើមលោកនាយកក្រុមហ៊ុនប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ និងសំណេះសំណាលជាមួយ និងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ប្រធានផ្នែក ប្រធានក្រុម ជាតំណាងឱ្យកម្មករ និយោជិត ដែលបានចូលរួមប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ។

**IV- លទ្ធផល**

ឆ្លងតាមការប្រជុំពិភាក្សារួចមក ភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោម៖

១-ភាគីទាំងពីរយល់ព្រមព្យួរកិច្ចសន្យាការងាររយៈពេលពីរខែ ចាប់ពីថ្ងៃទី០១ ខែមិនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ ចំនួន៣០០នាក់ ស្រី២៤៨នាក់ នៃកម្មករសរុប១១៨៨នាក់ ស្រី ៨១៩ ។

២-ក្រុមហ៊ុននឹងធ្វើការជូនដំណឹងទៅរាល់ប្រធានក្រុមទាំងអស់ ករណីមានការបញ្ជាទិញឡើងវិញបានក្នុងរយៈពេលព្យួរកិច្ចសន្យាការងារខាងលើ ។ ហើយប្រធានក្រុម គ្រប់ផ្នែកក្រុម ត្រូវធ្វើការទំនាក់ទំនងទៅ

សមាជិក ក្នុងក្រុមរបស់ខ្លួនដើម្បីជូនដំណឹងចូលធ្វើការ។

៣-ភាគីទាំងពីរយល់ព្រមទទួល យកការផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លារ (សាបសិបដុល្លារ ក្នុងមួយខែ ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារខាងលើនេះ ។

៤-ក្នុងករណីបងប្អូនកម្មករ មិនបានចូលធ្វើការវិញតាមការកំណត់នេះទេ ក្រុមហ៊ុននិងអនុវត្តតាមច្បាប់ស្តីពីការងារ និង បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ និង ស្និទ្ធស្នាលក្រៃលែង ។

| តំណាងក្រុមហ៊ុន | ប្រតិភូបុគ្គលិក | អ្នកធ្វើកំណត់ហេតុ |
| --- | --- | --- |
| ព្រះរាជាណាចក្រកម្ពុជា<br>ក្រុមហ៊ុន ប៊ូអ៊ី ហ្គាម៉ិន ឯ.ក<br>BOEEY GARMENT CO., LTD.<br>KINGDOM OF CAMBODIA<br>LIN SEN | [illegible handwritten names with thumbprints] | [signature] |